ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០១៧.៨៩៧ ស-ជ-ណ

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO) លើកទី ១៣

យោងតាមសេចក្តីជូនដំណឹងលេខ ធ៥.០១៧.៤១៥ ស-ជ-ណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការបង្កើនឥណប្រតិទានប្រតិបត្តិការ LPCO ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបអំពីការដេញថ្លៃប្រតិបត្តិការ LPCO ដូចតទៅ៖

- កាលបរិច្ឆេទដេញថ្លៃ : ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧
- ពេលវេលាដាក់ដេញថ្លៃ : ពីម៉ោង៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- ថ្ងៃប្រសិទ្ធភាពទូទាត់ : ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧
- ឥណប្រតិទាន : ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨
- ទឹកប្រាក់ដាក់ឲ្យដេញថ្លៃ : ២០.០០០.០០០.០០០ (ម្ភៃប៊ីលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអប្បបរមា/គ្រឹះស្ថាន : ២០០.០០០.០០០ (ពីររយលាន)រៀល
- ទឹកប្រាក់ដេញថ្លៃអតិបរមា/គ្រឹះស្ថាន : ៨.០០០.០០០.០០០ (ប្រាំបីប៊ីលាន)រៀល
- អត្រាការប្រាក់ដេញថ្លៃអប្បបរមា : ៣%
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល)និងអត្រាការប្រាក់ដេញថ្លៃជាភាគរយ(ពីរខ្ទង់ក្រោយក្បៀស)
- វត្ថុធានា : NCD (ជារៀលឬដុល្លារអាមេរិក)ត្រូវមានឥណប្រតិទានយ៉ាងតិច៣៦៤ថ្ងៃ។ NCDជាដុល្លារអាមេរិកត្រូវកំណត់ Haircut ៥% នៃទឹកប្រាក់ដែលដេញថ្លៃបាន។

ពាក្យសុំដេញថ្លៃត្រូវផ្ញើមកធនាគារជាតិនៃកម្ពុជា តាមរយៈសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬ តាមរយៈផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP)។ ក្នុងករណីមធ្យោបាយទាំងពីរនេះមិនដំណើរការ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើមកនាយកដ្ឋានប្រតិបត្តិការឲ្យបានមុនម៉ោង១២:០០ នាថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៧។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលបានជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣)៧២២ ២២១EX ១០៤៨
សារអេឡិចត្រូនិក :lpco_info@nbc.org.kh